ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ៤៧៤-សណ-១៧អអក

ភ្នំពេញ, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧

**សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**
**ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន**
**អគ្គិសនី ព្រះវិហារ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកត្បែងមានជ័យ**
**និងក្រុងព្រះវិហារ ខេត្តព្រះវិហារ**

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកត្បែងមានជ័យ និងក្រុងព្រះវិហារ ខេត្តព្រះវិហារ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម (ផលិតកម្ម និងចែកចាយ) ឲ្យក្រុមហ៊ុន អគ្គិសនី ព្រះវិហារ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកត្បែងមានជ័យ និងក្រុងព្រះវិហារ ខេត្តព្រះវិហារ ។ ពេលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យក្រុមហ៊ុន អគ្គិសនី ព្រះវិហារ ទិញអគ្គិសនីពីអគ្គិសនីកម្ពុជា មកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មរបស់ក្រុមហ៊ុន អគ្គិសនី ព្រះវិហារ លែងត្រូវការមធ្យោបាយផលិតកម្មទៀតហើយ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អគ្គិសនី ព្រះវិហារ ដោយប្តូរប្រភេទអាជ្ញាបណ្ណ ពីអាជ្ញាបណ្ណរួមមកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អគ្គិសនី ព្រះវិហារ ដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចនៅ.................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុកត្បែងមានជ័យ និងក្រុងព្រះវិហារ ខេត្តព្រះវិហារ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យក្រុមហ៊ុន អគ្គិសនី ព្រះវិហារ អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។ល។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ទី នរិទ្ធ**

អាជ្ញាធរអគ្គិសនីកម្ពុជា : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៩៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

ឣ អ ក

EAC

# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៥

**លើឯកសារអាជ្ញាបណ្ណលេខ ០៣១ ឯអ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ សម្រាប់ក្រុមហ៊ុន អគ្គិសនី ព្រះវិហារ ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកត្បែងមានជ័យ និងក្រុងព្រះវិហារ ខេត្តព្រះវិហារ**

**សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយ**

**DECISION ON THE FIFTH REVISION**

TO THE LICENSE DOCUMENT No.031 LD DATED MARCH 13, 2003 OF AKISANI PREAH VIHEAR CO., LTD FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF TBENG MEANCHEY DISTRICT AND KRONG PREAH VIHEAR, PREAH VIHEAR PROVINCE

**FOR CHANGING THE TYPE OF LICENSE**

**FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE**

ថ្ងៃទី      ខែ      ឆ្នាំ២០១៧

..... ....., 2017